# ជំងឺអុតស្វា

## សំណួរដែលបានសួរជាញឹកញាប់ (FAQs)

## 1. តើអ្វីទៅជាជំងឺអុតស្វា?

ជំងឺអុតស្វាគឺជាប្រភេទជំងឺឆ្លងមួយដែលបង្កឡើងដោយមេរោគអុតស្វា។ ជំងឺអុតស្វាស្ថិតនៅក្នុងក្រុមមេរោគដូចគ្នាទៅនឹងមេរោគដែលបង្កឱ្យមានជំងឺអុតតូច (variola) ផងដែរ។ រោគសញ្ញានានានៃជំងឺអុតស្វា និងជំងឺអុតតូចគឺមានភាពស្រដៀងគ្នា ប៉ុន្តែរោគសញ្ញានានានៃជំងឺអុតស្វាគឺមានកម្រិតស្រាលជាង និងកម្រនឹងមានគ្រោះថ្នាក់ដល់ជីវិត។ ជំងឺអុតស្វាមិនទាក់ទងទៅនឹងជំងឺអុតស្វាយ (chickenpox) នោះទេ។

មានការរកឃើញជំងឺអុតស្វាជាលើកដំបូងនៅឆ្នាំ 1958 ក្នុងចំណោមហ្វូងស្វាជាច្រើនដែលត្រូវបានរក្សាទុកក្នុងគោលបំណងសម្រាប់ការស្រាវជ្រាវ។ មានការធ្វើកំណត់ត្រាថាករណីជំងឺនេះកើតឡើងនៅលើមនុស្សជាលើកដំបូងគឺនៅឆ្នាំ 1970។ នាពេលកន្លងមក មានការធ្វើកំណត់ត្រាថាជំងឺអុតស្វាបានកើតឡើងចំពោះមនុស្សនៅក្នុងប្រទេសមួយចំនួននៅតំបន់កណ្ដាល និងតំបន់ខាងលិចនៃទ្វីបអាហ្វ្រិក។ ស្ទើរតែគ្រប់ករណីនៃជំងឺអុតស្វាទាំងអស់នៅលើមនុស្សនៅក្នុងសហរដ្ឋអាមេរិក មានការពាក់ព័ន្ធទៅនឹងការធ្វើដំណើរក្រៅប្រទេស ទៅកាន់កន្លែងដែលជំងឺនេះត្រូវបានដឹងថាអាចកើតមានឡើង ឬក៏តាមរយៈសត្វដែលបាននាំយកចូលមក។

ទោះជាយ៉ាងណាក៏ដោយ ចាប់តាំងពីខែឧសភា ឆ្នាំ 2022 មកនោះ មានការផ្ទុះឡើងយ៉ាងធំនៃជំងឺអុតស្វានៅតាមប្រទេសជាច្រើន រួមមានទាំងសហរដ្ឋអាមេរិក ផងដែរ។ វិធីចម្បងដែលមនុស្សទាំងឡាយឆ្លងមេរោគនេះគឺតាមរយៈទំនាក់ទំនងជិតស្និទ្ធ ឬការប៉ះពាល់ដោយស្និទ្ធស្នាល ជាមួយនឹងមនុស្សដែលមានរោគសញ្ញា ជាពិសេសក្នុងអំឡុងពេលរួមភេទ។ ខណៈពេលដែលបុគ្គលមួយចំនួនអាចធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរ បុគ្គលភាគច្រើនមិនត្រូវការ ការសម្រាកព្យាបាលនៅមន្ទីរពេទ្យនោះទេ ហើយចាប់ផ្តើមជាសះស្បើយក្នុងរយៈពេល 2 ទៅ 4 សប្តាហ៍។ ថ្នាំបង្ការ និងថ្នាំព្យាបាលប្រឆាំងនឹងមេរោគ (antiviral treatment) ក៏មានផ្តល់ជូនសម្រាប់ជំងឺអុតស្វា ផងដែរ។

សំណួរដែលបានសួរជាញឹកញាប់ (FAQs) ទាំងឡាយខាងក្រោមនេះ គឺទាក់ទងទៅនឹងការផ្ទុះឡើងនៃជំងឺអុតស្វានៅក្នុងសហរដ្ឋអាមេរិក នាឆ្នាំ 2022 នេះ។

## 2. តើជំងឺអុតស្វាមានសញ្ញា និងរោគសញ្ញាអ្វីខ្លះ?

រោគសញ្ញានានានៃជំងឺអុតស្វា ជាធម្មតា ចាប់ផ្តើមលេចឡើងក្នុងអំឡុងពេល 3 សប្តាហ៍នៃការប៉ះពាល់ទៅនឹងមេរោគនោះ។

រោគសញ្ញាដែលកើតឡើងទូទៅបំផុត គឺកន្ទួលរមាស់ដែលអាចនឹង៖

- មើលទៅដូចជាឡើងដុំពក មុន (លើស្បែក) ពងបែក ឬមានឡើងក្រមរ។ កន្ទួលរមាស់នេះនឹងត្រូវឆ្លងកាត់ជាច្រើនដំណាក់កាល មុនពេលចាប់ផ្តើមជាសះស្បើយ។ ជាធម្មតា កន្ទួលរមាស់មានពណ៌ក្រហម និងមានរាងជាដុំអុជរាបស្មើ នៅពេលចាប់ផ្តើមលេចចេញដំបូង ហើយបន្ទាប់មកក្លាយទៅជាដុំពក។ ដុំពកទាំងនោះអាចនឹងក្លាយទៅជាមានសារធាតុរាវនៅខាងក្នុង ហើយដែលបង្កទៅជាខ្ទុះ។ បន្ទាប់មកដុំពកទាំងនោះឡើងក្រៀមពីខាងក្រៅ ហើយក្លាយទៅជាក្រមរដំបៅ។
- ចេញនៅខាងលើ ឬនៅជិតប្រដាប់ភេទ (លិង្គ ពងស្វាស មាត់ទ្វារមាស និងទ្វារមាស) ទ្វារធំ (រន្ធគូទ) មាត់ ឬនៅតំបន់ផ្សេងៗទៀតដូចជាដៃ ជើង ទ្រូង និងមុខជាដើម។
- រីករាលដាលនៅពាសពេញដងខ្លួន ឬអាចនឹងឡើងនៅតែនឹងមួយកន្លែង។ ការឡើងកន្ទួលរមាស់នោះអាចគ្រាន់តែជាដុំពក ឬពងបែកមួយចំនួន។
- មានការឈឺចាប់ និង/ឬការរមាស់។ មនុស្សមួយចំនួនមានការឈឺចាប់កម្រិតធ្ងន់ធ្ងរ ជាពិសេស ប្រសិនបើកន្ទួលរមាស់នោះស្ថិតនៅខាងក្នុងមាត់ ឬក្នុងទ្វារធំរបស់ពួកគេ។

មនុស្សមួយចំនួនក៏អាចនឹងចេញរោគសញ្ញាដែលដូចគ្នាទៅនឹងជំងឺគ្រុនផ្តាសាយធំ (flu) បន្ថែមពីលើកន្ទួលរមាស់នេះ ផងដែរ។ រោគសញ្ញាទាំងនេះអាចនឹងលេចឡើងក្នុងចន្លោះពេលពី 1 ទៅ 4 ថ្ងៃ មុនពេលកន្ទួលរមាស់ចាប់ផ្តើម ឬបន្ទាប់ពីកន្ទួលរមាស់បានចាប់ផ្តើមហើយ។ រោគសញ្ញាទាំងនោះរួមមានដូចជា គ្រុនក្តៅឬគ្រុនរងា ហើមកូនកណ្តុរ អស់កម្លាំង ឈឺសាច់ដុំ និងឈឺក្បាល ផងដែរ។

មនុស្សភាគច្រើនដែលមានជំងឺអុតស្វា ចាប់ផ្តើមជាសះស្បើយឡើងវិញក្នុងរយៈពេល 2 ទៅ 4 សប្តាហ៍។

ដើម្បីមើលរូបភាពផ្សេងៗនៃកន្ទួលរមាស់ទាក់ទងទៅនឹងជំងឺអុតស្វា សូមចូលទៅកាន់ឯកសារសំណួរដែលបានសួរជាញឹកញាប់ទាំងនេះ នៅលើគេហទំព័រ ph.lacounty.gov/monkeypox។

## 3. តើជំងឺអុតស្វារីករាលដាលតាមវិធីណាខ្លះ?

វិធីចម្បងដែលជំងឺអុតស្វារីករាលដាលគឺតាមរយៈទំនាក់ទំនងជិតស្និទ្ធ ឬការប៉ះពាល់ដោយស្និទ្ធស្នាល ជាមួយនឹង

មនុស្សដែលមានរោគសញ្ញា ជាពិសេសក្នុងអំឡុងពេលរួមភេទ។

ជំងឺអុតស្វាអាចរីករាលដាលបាន តាមរយៈ៖

- ការប៉ះពាល់ស្បែកនឹងស្បែកដោយផ្ទាល់ជាមួយនឹងកន្ទួលរមាស់ ឬក្រមដំបៅរបស់បុគ្គលម្នាក់ដែលមានជំងឺអុតស្វា។
- ការប៉ះពាល់ដោយផ្ទាល់ជាមួយនឹងសារធាតុរាវផ្សេងៗពីរាងកាយ ឬសារធាតុរាវផ្សេងៗដែលចេញតាមផ្លូវដង្ហើមពីបុគ្គលម្នាក់ដែលមានជំងឺអុតស្វា ដូចជាសារធាតុរាវ (ទឹករងៃ) ដែលហៀរចេញពីដំបៅនៅលើស្បែក ឬទឹកមាត់ដែលបានប៉ះពាល់ជាមួយនឹងដំបៅនៅក្នុងមាត់។
- ការមុត/ចាក់ធ្លុះដោយវត្ថុមុតស្រួចមួយ (ដូចជាម្ជុល) ដែលបានប៉ះពាល់ជាមួយនឹងដំបៅ ឬសារធាតុរាវផ្សេងៗពីរាងកាយរបស់បុគ្គលម្នាក់ដែលមានជំងឺអុតស្វា។
- ការប៉ះពាល់សាច់ក្រណាត់ (ដូចជាកម្រាលពូកឬស្រោមខ្នើយ កន្សែងជូតខ្លួន ឬក៏សម្លៀកបំពាក់) ដែលបានប៉ះពាល់ជាមួយនឹងដំបៅ ឬសារធាតុរាវផ្សេងៗពីរាងកាយរបស់បុគ្គលម្នាក់ដែលមានជំងឺអុតស្វា ហើយមិនទាន់បានបោកគក់សម្អាត ឬលាងសម្អាតរួចនោះ។ (កំណត់សម្គាល់៖ មជ្ឈមណ្ឌលគ្រប់គ្រងនិងទប់ស្កាត់ជំងឺឆ្លង [CDC] បញ្ជាក់ថាហានិភ័យនៃការឆ្លងជំងឺអុតស្វាក្នុងវិធីនេះគឺមានកម្រិតទាប។)

បុគ្គលម្នាក់ដែលមានជំងឺអុតស្វា អាចចម្លងមេរោគនេះបន្តទៅកាន់អ្នកផ្សេងទៀតបាន គិតចាប់តាំងពីពេលដែលចាប់ផ្តើមកើតមានរោគសញ្ញានានា រហូតដល់ពេលកន្ទួលរមាស់បានជាសះស្បើយទាំងស្រុង និងមានស្រទាប់ស្បែកថ្មីដុះឡើងវិញ។ ជាធម្មតា ត្រូវការរយៈពេលចន្លោះពី 2 ទៅ 4 សប្តាហ៍។

បុគ្គលដែលមានផ្ទៃពោះ ហើយដែលមានផ្ទុកជំងឺអុតស្វា អាចចម្លងមេរោគនេះបន្តទៅទារកនៅក្នុងផ្ទៃរបស់ពួកគេបាន តាមរយៈសុក។ មេរោគនេះក៏អាចចម្លងទៅដល់ទារកតាមរយៈការប៉ះពាល់ជិតស្និទ្ធ ក្នុងអំឡុងពេល និងក្រោយពេលសម្រាល ផងដែរ។

**អ្នកវិទ្យាសាស្ត្រនៅតែកំពុងស្រាវជ្រាវបន្ថែមទៀតអំពីវិធីដែលជំងឺអុតស្វារីករាលដាល ដែលរួមមានដូចជា៖**

- ថាតើមេរោគនេះអាចរីករាលដាលបាននៅពេលដែលអ្នកជំងឺមិនមានចេញ រោគសញ្ញានានា ឬយ៉ាងណា (មកដល់ពេលនេះ មិនមានភ័ស្តុតាងថាចំណុចនេះកំពុងកើតមាននោះទេ)
- ថាតើមេរោគនេះអាចរីករាលដាលតាមរយៈសារធាតុរាវផ្សេងៗតាមផ្លូវដង្ហើមញឹកញាប់កម្រិតណា
- ថាតើជំងឺអុតស្វាអាចរីករាលដាលតាមរយៈទឹកកាម សារធាតុរាវពីទ្វារមាស ទឹកនោម ឬក៏លាមក ឬទេ។

សូមមើលគេហទំព័រ វិធីដែលជំងឺអុតស្វារីករាលដាល របស់ CDC សម្រាប់ព័ត៌មានបន្ថែម។

## 4. តើអ្នកណាខ្លះ ប្រឈមនឹងហានិភ័យនៃការឆ្លងជំងឺអុតស្វា?

ក្នុងអំឡុងពេលនៃការផ្ទុះឡើងនៃជំងឺនៅក្នុងសហរដ្ឋអាមេរិក នាពេលបច្ចុប្បន្ននេះ បុគ្គលភាគច្រើនដែលបានពិនិត្យឃើញថាមានផ្ទុកជំងឺអុតស្វា គឺជាមនុស្សប្រុសដែលត្រូវបានរាយការណ៍ថាមានការរួមភេទ ឬការប៉ះពាល់ដោយស្និទ្ធស្នាលជាមួយនឹងមនុស្សប្រុសដទៃទៀត។ ប៉ុន្តែបុគ្គលណាក៏ដោយ មិនថាបុគ្គលនោះស្រឡាញ់ភេទអ្វី ឬមានអត្តសញ្ញាណភេទអ្វីឡើយ គឺប្រឈមនឹងហានិភ័យ ប្រសិនបើពួកគេមានទំនាក់ទំនងជិតស្និទ្ធ និងការប៉ះពាល់ស្បែកនឹងស្បែកដោយស្និទ្ធស្នាលជាមួយនឹងនរណាម្នាក់ដែលមានជំងឺអុតស្វា ហើយដែលមានចេញរោគសញ្ញានានា។

ដោយសារតែការផ្ទុះឡើងនៃជំងឺនេះគឺជារឿងថ្មីមួយ អង្គការសុខភាពសាធារណៈទាំងថ្នាក់ជាតិ និងថ្នាក់អន្តរជាតិបានកំពុងតែធ្វើការសិក្សាស្វែងយល់អំពីស្ថានភាព ឬសកម្មភាពនានាដែលអាចនឹងធ្វើឱ្យមនុស្សមានការប្រឈមនឹងហានិភ័យនៃការឆ្លងខ្ពស់ជាងមុន។ យើងខ្ញុំនឹងបន្តចែករំលែកព័ត៌មាន នៅពេលដែលបានស្វែងយល់បន្ថែមអំពីជំងឺនោះ។ ព័ត៌មានបន្ថែមអាចរកបាននៅក្នុង សេចក្តីសង្ខេបផ្នែកវិទ្យាសាស្ត្រ៖ ការស្វែងរក និងការចម្លងនៃជំងឺអុតស្វា របស់មជ្ឈមណ្ឌលគ្រប់គ្រងនិងទប់ស្កាត់ជំងឺឆ្លង (CDC)។

## 5. តើជំងឺអុតស្វាអាចព្យាបាលបានយ៉ាងដូចម្តេច?

នៅមិនទាន់មានថ្នាំពេទ្យ ដែលបានទទួលការអនុម័តឱ្យប្រើប្រាស់ពីរដ្ឋបាលចំណីអាហារនិងឱសថ (FDA) សម្រាប់ការព្យាបាលជំងឺអុតស្វាចំតែម្តងនៅឡើយទេ។ ប៉ុន្តែថ្នាំព្យាបាលប្រឆាំងនឹងមេរោគដែលបានទទួលការអនុម័តឱ្យប្រើប្រាស់ពី FDA សម្រាប់ការព្យាបាលជំងឺអុតតូច (smallpox) ដែលមានឈ្មោះថា tecovirimat (ឬប្រភេទ TPOXX) អាចប្រើប្រាស់សម្រាប់ព្យាបាលអ្នកដែលមានជំងឺអុតស្វាបាន។ ថ្នាំប្រភេទ TPOXX មានផ្តល់ជូនបុគ្គលដែលមានជំងឺអុតស្វាកម្រិតធ្ងន់ធ្ងរ រួមទាំងដំបៅនៅក្នុងតំបន់ដែលងាយនឹងឈឺចាប់ខ្លាំង ឬការឈឺចាប់ដែលមិនអាចគ្រប់គ្រងបានដោយការប្រើប្រាស់ថ្នាំពេទ្យដែលអាចទិញបានដោយមិនចាំបាច់មានវេជ្ជបញ្ជា។ ថ្នាំប្រភេទនេះក៏អាចផ្តល់ជូនបុគ្គលដែលទំនងនឹងធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរផងដែរ (សូមមើលសំណួរ *តើអ្នកណាខ្លះ ដែលប្រឈមនឹងហានិភ័យខ្ពស់ជាងមុននៃការធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរ?* នៅខាងក្រោម)។ ស្វែងយល់បន្ថែមនៅគេហទំព័រ ការណែនាំសម្រាប់

អ្នកជំងឺ ចំពោះការព្យាបាលជំងឺអុតស្វាដោយថ្នាំប្រភេទ TPOXX របស់មជ្ឈមណ្ឌលគ្រប់គ្រងនិងទប់ស្កាត់ជំងឺឆ្លង (CDC)។

ប្រសិនបើអ្នកមានជំងឺអុតស្វា គ្រូពេទ្យរបស់អ្នកក៏អាចចេញវេជ្ជបញ្ជាសម្រាប់ទទួលថ្នាំពេទ្យដែលមិនមែនសម្រាប់ជំងឺអុតស្វា ហើយដែលអាចជួយកាត់បន្ថយការឈឺចាប់ និងការក្រហាយពីការរមាស់ ឬដំបៅបានផងដែរ។ សម្រាប់ព័ត៌មានអំពីវិធីគ្រប់គ្រងរោគសញ្ញានានារបស់អ្នក សូមចូលទៅកាន់គេហទំព័រ អ្វីដែលត្រូវធ្វើ ប្រសិនបើអ្នកធ្លាក់ខ្លួនឈឺ របស់ CDC។

## 6. តើអ្វីទៅជាជំងឺអុតស្វាកម្រិតធ្ងន់ធ្ងរ?

មនុស្សជាច្រើនដែលមានជំងឺអុតស្វា មានជំងឺកម្រិតស្រាល ប៉ុន្តែសម្រាប់មនុស្សមួយចំនួនផ្សេងទៀតដែលមានជំងឺអុតស្វា អាចនឹងមានជំងឺកម្រិតធ្ងន់ធ្ងរ។ សញ្ញានានានៃជំងឺអុតស្វាកម្រិតធ្ងន់ធ្ងរ អាចរួមមានដូចជា៖

- កន្ទួលរមាស់ ឬដំបៅនៅលើ ឬនៅក្បែរភ្នែក
- កន្ទួលរមាស់ដែលរីករាលដាលពាសពេញដងខ្លួន ឬរួមផ្គុំចូលគ្នានៅនឹងផ្នែកណាមួយនៅលើដងខ្លួន
- ការឈឺចាប់នៅក្នុងចុងពោះវៀនធំ (ទ្វារធំ) ឬទ្វារតូច (បំពង់ទឹកនោម) ដែលធ្វើឱ្យមានការពិបាកក្នុងការបត់ជើងនៅក្នុងបន្ទប់ទឹក
- ការឈឺចាប់នៅក្នុងមាត់ ដែលធ្វើឱ្យពិបាកក្នុងការទទួលទានអាហារ និងភេសជ្ជៈ
- កន្ទួលរមាស់ដែលមានចេញឈាម ឬមើលទៅដូចជាមានឆ្លងមេរោគ
- រោគសញ្ញាដែលកាន់តែធ្ងន់ធ្ងរទៅៗ ឬមិនបានធូរស្បើយទោះបីជាកន្លងផុតទៅមួយរយៈហើយក៏ដោយ

សូមស្វែងរកជំនួយផ្នែកសុខភាពភ្លាមៗ ប្រសិនបើអ្នកមានចេញរោគសញ្ញាណាមួយក្នុងចំណោមរោគសញ្ញាទាំងនេះ ឬមានរោគសញ្ញាផ្សេងទៀតដែលបង្កការព្រួយបារម្ភដល់អ្នក។ ប្រសិនបើអ្នកមានជំងឺហ៊ីវ (HIV) ដែលមិនបានគ្រប់គ្រងត្រឹមត្រូវ ឬមានកម្រិតធ្ងន់ធ្ងរនោះ សូមទៅជួបជាមួយនឹងគ្រូពេទ្យភ្លាមៗ បើទោះបីជារោគសញ្ញានានានៃជំងឺអុតស្វារបស់អ្នកហាក់បីដូចជាមានកម្រិតស្រាលក៏ដោយ។

## 7. តើអ្នកណាខ្លះ ដែលប្រឈមនឹងហានិភ័យខ្ពស់ជាងមុននៃការធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរ?

មនុស្សទាំងឡាយណាដែលកំពុងកើតមានជំងឺហ៊ីវ (HIV) ដែលមិនបានគ្រប់គ្រងត្រឹមត្រូវ ឬមានកម្រិតធ្ងន់ធ្ងរ ប្រឈមនឹងហានិភ័យខ្ពស់នៃការធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរ ប្រសិនបើពួកគេកើតជំងឺអុតស្វានោះ។ មនុស្សផ្សេងទៀតដែលមានប្រព័ន្ធភាពស៊ាំចុះខ្សោយ ក៏ត្រូវបានចាត់ទុកថាប្រឈមនឹងហានិភ័យខ្ពស់នៃការធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរ ផងដែរ។

មនុស្សទាំងឡាយណាដែលកើតជំងឺអុតស្វា ហើយមានដំបៅនៅលើភ្នែក ក្នុងមាត់ ក្នុងចុងពោះវៀនធំ និង/ឬលើប្រដាប់ភេទ អាចមានការឈឺចាប់ ឬការឡើងហើមធ្ងន់ធ្ងរ។ កន្លែងទាំងនេះអាចក្លាយទៅជាមានឆ្លងមេរោគ។ ហានិភ័យនៃការចេញស្នាមសម្លាក ក៏អាចកើតមានផងដែរ។

ជាងនេះទៅទៀត ផ្អែកទៅលើអ្វីដែលយើងបានដឹងអំពីការផ្ទុះឡើងនៃជំងឺអុតស្វានាពេលកន្លងមក ក្រុមមនុស្សដូចខាងក្រោមនេះអាចប្រឈមនឹងហានិភ័យខ្ពស់ជាងមុននៃការកើតមានជំងឺអុតស្វាកម្រិតធ្ងន់ធ្ងរ ប្រសិនបើពួកគេឆ្លងជំងឺនេះ។ ពួកយើងនៅមិនទាន់ដឹងនៅឡើយទេថា ហានិភ័យនៃការធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរ របស់ពួកគេអាចនឹងឈានដល់កម្រិតណានៅអំឡុងពេលនៃការផ្ទុះឡើងនៃជំងឺ នាពេលឥឡូវនេះ។

- មនុស្សទាំងឡាយណាដែលមានប្រព័ន្ធភាពស៊ាំចុះខ្សោយ (មានប្រព័ន្ធភាពស៊ាំទន់ខ្សោយ ដោយសារតែការព្យាបាល ឬជំងឺប្រចាំខ្លួន ឬក៏ការឆ្លងមេរោគមួយ)។
- មនុស្សទាំងឡាយណាដែលមានជំងឺ ឬស្ថានភាពសុខភាពមួយដែលប៉ះពាល់ដល់ស្បែកដូចជារោគត្រអក (eczema) ឬការរលាកស្បែកដោយសារតែមានប្រតិកម្មឬការទាស់ទៅនឹងសារធាតុអ្វីមួយ (atopic dermatitis) ឬជំងឺស្បែករ៉ាំរ៉ៃដែលបង្កឱ្យមានការបែកស្រកានិងឡើងរមាស់ជាផ្នែកៗ (psoriasis) ឬបញ្ហាឆ្លងមេរោគទៅក្នុងស្បែកដែលបង្កឱ្យមានដុំអុជតូចៗដែលភាគច្រើនកើតឡើងទៅជុំវិញមាត់និងច្រមុះរបស់កុមារ (impetigo) ឬការឡើងមុនលើស្បែកកម្រិតធ្ងន់ធ្ងរ ឬរោគស្វាយ (herpes) ឬក៏ការរលាកស្បែកផ្សេងៗ។
- កុមារទាំងឡាយ ជាពិសេសកុមារដែលមានអាយុក្រោម 8 ឆ្នាំ។
- បុគ្គលទាំងឡាយដែលកំពុងមានផ្ទៃពោះ ឬកំពុងបំបៅកូនដោយទឹកដោះ។

ក្នុងអំឡុងពេលនៃការផ្ទុះឡើងនៃជំងឺ នាពេលបច្ចុប្បន្ននេះ មនុស្សភាគច្រើនដែលមានជំងឺអុតស្វាគឺជាមនុស្សពេញវ័យភេទប្រុស ហើយនិងមិនបានតម្រូវចាំបាច់ឱ្យចូលសម្រាកព្យាបាលនៅមន្ទីរពេទ្យឡើយ។ នោះជាយ៉ាងណាក៏ដោយ ករណីនៃជំងឺអុតស្វាកម្រិតធ្ងន់ធ្ងរ រួមទាំងការស្លាប់មួយចំនួនផងដែរនោះ បានកើតមានឡើយនៅលើ

មនុស្សដែលមានប្រព័ន្ធភាពស៊ាំចុះទន់ខ្សោយកម្រិតធ្ងន់ធ្ងរ។ ចំណុចនេះរួមមានទាំងអ្នកដែលកំពុងមានជំងឺ HIV ដែលមិនបានព្យាបាល ឬមានកម្រិតធ្ងន់ធ្ងរ ផងដែរ។

## 8. តើខ្ញុំគួរតែធ្វើអ្វីខ្លះ ប្រសិនបើខ្ញុំគិតថាខ្ញុំមានជំងឺអុតស្វា?

សូមទាក់ទងទៅគ្រូពេទ្យរបស់អ្នកភ្លាមៗ ប្រសិនបើអ្នកមានចេញកន្ទួលរមាស់ ឬដំបៅថ្មីមួយ ដែលខុសប្រក្រតីនៅលើផ្នែកណាមួយនៃដងខ្លួនរបស់អ្នក។ ការធ្វើបែបនេះមានសារៈសំខាន់ជាពិសេស ប្រសិនបើអ្នកបានប៉ះពាល់ទៅនឹងនរណាម្នាក់ដែលមានជំងឺអុតស្វា ឬមានការសង្ស័យថាមានផ្ទុកជំងឺអុតស្វា។ គ្របដណ្តប់កន្ទួលរមាស់ទាំងអស់ឱ្យបានជិតល្អដោយសម្លៀកបំពាក់ ស្រោមដៃ និង/ឬបង់រុំរបួស ហើយនិងអនុវត្តតាមវិធានការណ៍នានាដើម្បីការពារអ្នកដទៃ។ ក្នុងនោះរួមមានដូចជាការជៀសវាងការប៉ះពាល់ស្បែកនឹងស្បែក ហើយនិងទំនាក់ទំនងផ្លូវកាយដោយស្និទ្ធស្នាល ជាមួយនឹងនរណាម្នាក់ រហូតដល់ពេលដែលអ្នកទទួលការពិនិត្យដោយគ្រូពេទ្យបានច្បាស់លាស់ហើយនោះ។ ត្រូវប្រាកដថាមានពាក់ម៉ាស់ នៅពេលអ្នកទៅជួបជាមួយនឹងគ្រូពេទ្យ។

សូមទូរស័ព្ទទៅកាន់ មជ្ឈមណ្ឌលផ្តល់ព័ត៌មានរបស់នាយកដ្ឋានសុខភាពសាធារណៈ (Public Health Call Center) តាមរយៈលេខ 1-833-540-0473 (ដែលមានបើកបម្រើការជូនជារៀងរាល់ថ្ងៃ ចាប់ពីម៉ោង 8 ព្រឹក ដល់ម៉ោង 8:30 យប់) ប្រសិនបើអ្នកមិនមានគ្រូពេទ្យប្រចាំខ្លួន ឬធានារ៉ាប់រងសុខភាពទេ។ ប្រសិនបើអ្នកកើតមានកន្ទួលរមាស់ អ្នកក៏អាចទទួលបានសេវាកម្មផ្សេងៗនៅ គ្លីនិកផ្នែកសុខភាពផ្លូវភេទរបស់សុខភាពសាធារណៈផងដែរ (សូមមើលកាលវិភាគ នៅទីនេះ)។

រហូតដល់ពេលដែលអ្នកដឹងថា អ្នកមិនមានជំងឺអុតស្វាទេនោះ សូមអនុវត្តតាមវិធានការណ៍ដើម្បីកាត់បន្ថយហានិភ័យនៃការចម្លងមេរោគ ដោយការនៅឱ្យបានឆ្ងាយពីអ្នកដទៃ។ សូមមើលគេហទំព័រ សេចក្តីណែនាំអំពីការដាក់ខ្លួនឱ្យនៅដាច់ដោយឡែកសម្រាប់បុគ្គលដែលមានជំងឺអុតស្វា។

## 9. តើអ្នកអាចធ្វើតេស្តរកមេរោគអុតស្វាបាន ដោយវិធីណាខ្លះ?

ប្រសិនបើអ្នកមានកន្ទួលរមាស់ដែលប្រហែលជាអាចនឹងបង្កឡើងដោយសារជំងឺអុតស្វានោះ គ្រូពេទ្យរបស់អ្នកនឹងធ្វើការពិនិត្យជូនអ្នក។ ដោយផ្អែកទៅលើការវាយតម្លៃ ពួកគេអាចនឹងយកសំឡីត្បារមកផ្តិតនៅលើកន្ទួលរមាស់របស់អ្នក សម្រាប់ការធ្វើតេស្តរកមេរោគ។ បន្ទាប់មកពួកគេនឹងបញ្ជូនសំឡីត្បារទាំងនោះទៅកាន់មន្ទីរពិសោធន៍មួយ ហើយលទ្ធផលតេស្តគួរតែនឹងផ្តល់ជូនអ្នកក្នុងរយៈពេលប៉ុន្មានថ្ងៃក្រោយមក។ សម្រាប់ពេលនេះ នៅមិនទាន់មានប្រភេទតេស្តដែលអាចធ្វើដោយខ្លួនឯង ឬដែលអាចធ្វើនៅតាមផ្ទះបាន សម្រាប់ពិនិត្យរកមេរោគអុតស្វានៅឡើយទេ។

រហូតដល់ពេលដែលអ្នកដឹងថាអ្នកមិនមានជំងឺអុតស្វា ការអនុវត្តន៍តាម សេចក្តីណែនាំសម្រាប់ការដាក់ខ្លួនឱ្យនៅដាច់ដោយឡែកទាក់ទងនឹងជំងឺអុតស្វា មានសារៈសំខាន់ណាស់។

## 10. តើខ្ញុំគួរតែធ្វើអ្វីខ្លះ ប្រសិនបើខ្ញុំបានពិនិត្យឃើញថាមានផ្ទុកជំងឺអុតស្វា?

ប្រសិនបើអ្នកបានពិនិត្យឃើញថាមានផ្ទុកជំងឺអុតស្វា អ្នកគួរតែដាក់ខ្លួនឱ្យនៅដាច់ដោយឡែក ដើម្បីការពារអ្នកដទៃ។ សូមអនុវត្តតាម សេចក្តីណែនាំអំពីការដាក់ខ្លួនឱ្យនៅដាច់ដោយឡែកសម្រាប់បុគ្គលដែលមានជំងឺអុតស្វា ដែលមានផ្តល់ជូនជាច្រើនភាសា នៅលើគេហទំព័រ ph.lacounty.gov/monkeypox។

សូមទាក់ទងទៅដៃគូរួមភេទទាំងឡាយរបស់អ្នក និងបុគ្គលណាម្នាក់ដែលអ្នកមានទំនាក់ទំនងជិតស្និទ្ធខ្លាំងជាមួយ ព្រមទាំងអ្នកដែលមានការប៉ះពាល់ដោយស្និទ្ធស្នាល និង/ឬអ្នកដែលមានទំនាក់ទំនងរយៈពេលយូរជាមួយគិតចាប់តាំងពីការចាប់ផ្តើមលេចឡើងនៃរោគសញ្ញានានារបស់អ្នក។ សូមធ្វើបែបនេះ ឱ្យបានកាន់តែឆាប់តាមដែលអាចធ្វើទៅបាន ដើម្បីឱ្យពួកគេអាចពិចារណាទទួល ចាក់ថ្នាំបង្ការ (ប្រសិនបើពួកគេមិនទាន់កើតជំងឺអុតស្វា ឬក៏មិនទាន់បានទទួលចាក់ថ្នាំបង្ការសម្រាប់ជំងឺអុតស្វាទេនោះ)។ ការទទួលចាក់ថ្នាំបង្ការក្រោយការប៉ះពាល់ទៅនឹងមេរោគ អាចទប់ស្កាត់ការកើតមានជំងឺអុតស្វា ឬក៏ធ្វើឱ្យជំងឺនោះមានកម្រិតស្រាលជាងមុន។ ពួកគេក៏អាចនឹងតាមដានរកមើលរោគសញ្ញានានានៃជំងឺអុតស្វាផងដែរ។

សូមទទួលទូរស័ព្ទពីនាយកដ្ឋានសុខភាពសាធារណៈ (Public Health) (ប្រសិនបើមានការទាក់ទងទៅ)។ ពួកគេនឹងទាក់ទងទៅអ្នកដើម្បីសាកសួរអំពីសកម្មភាពផ្សេងៗរបស់អ្នកមុន និងក្រោយពេលដែលអ្នកកើតមានរោគសញ្ញានានា។ ការសាកសួរនេះគឺដើម្បីស្វែងរកមើលថាតើអ្នកអាចនឹងបានប៉ះពាល់ទៅនឹងមេរោគអុតស្វាដោយវិធីណា និងដើម្បីជួយកំណត់អត្តសញ្ញាណបុគ្គលទាំងឡាយផ្សេងទៀតដែលអាចនឹងបានប៉ះពាល់ទៅនឹងមេរោគ ផងដែរ។

## 11. តើខ្ញុំអាចកាត់បន្ថយកម្រិតហានិភ័យនៃការឆ្លងជំងឺអុតស្វារបស់ខ្ញុំបានយ៉ាងដូចម្តេច?

មានវិធីជាច្រើនដើម្បីកាត់បន្ថយហានិភ័យនៃជំងឺអុតស្វាបាន៖

- ទទួលចាក់ថ្នាំបង្ការ ប្រសិនបើអ្នកមានសិទ្ធិ (សូមមើលសំណួរខាងក្រោម)
- ជៀសវាងទំនាក់ទំនងជិតស្និទ្ធខ្លាំង និងការប៉ះពាល់ដោយស្និទ្ធស្នាលជាមួយនឹងនរណាម្នាក់ដែលមានរោគសញ្ញានានានៃជំងឺអុតស្វា ជាពិសេស៖
  - ការរួមភេទតាមមាត់ តាមទ្វារធំ និងតាមទ្វារមាស ឬការប៉ះពាល់ជាមួយនឹងប្រដាប់ភេទ ឬទ្វារធំ
  - ការឱប ការឱបដោយថ្នាក់ថ្នម (cuddling) ការម៉ាស្សា និង/ឬការថើប
  - ការប៉ះពាល់ស្បែកនឹងស្បែក ជាមួយនឹងកន្ទួលរមាស់នៅលើដងខ្លួនរបស់ពួកគេ
  - ការប្រើប្រាស់កន្សែងជូតខ្លួន សម្លៀកបំពាក់ កម្រាលពូកឬស្រោមខ្នើយ ភួយ ឬក៏វត្ថុនិងសម្ភារៈដទៃទៀតរួមគ្នា (ឧ. ច្រាសដុសធ្មេញ ពែងទឹក ប្រដាប់ប្រដាផ្ទះបាយ និងប្រដាប់ប្រដាលេងពេលរួមភេទ [sex toys]) ដែលមិនទាន់បានបោកគក់សម្អាត ឬលាងសម្អាតរួច។
- លាងសម្អាតដៃ ឬប្រដាប់ប្រដាសម្រាប់ដាស់ចំណង់ចំណូលចិត្ត (fetish gear) ឬប្រដាប់ប្រដាលេងពេលរួមភេទ និងសាច់ក្រណាត់ណាមួយ (ដូចជាកម្រាលពូកឬស្រោមខ្នើយ កន្សែងជូតខ្លួន ឬក៏សម្លៀកបំពាក់) របស់អ្នក ក្រោយពេលរួមភេទរួច។
- ពាក់ឧបករណ៍ការពារឱ្យបានត្រឹមត្រូវ (ដូចជាម៉ាស់ ស្រោមដៃ និងអាវវែងការពារ) ប្រសិនបើអ្នកមិនអាចជៀសវាងពីទំនាក់ទំនងជិតស្និទ្ធជាមួយនឹងនរណាម្នាក់ដែលមានរោគសញ្ញានានានៃជំងឺអុតស្វាបានទេនោះ។
- និយាយជាមួយដៃគូរួមភេទរបស់អ្នក (មួយ ឬច្រើន) អំពីជំងឺថ្មីៗណាមួយ និងដំបៅ ឬកន្ទួលរមាស់ដែលកើតមានថ្មី ឬដែលខុសប្រក្រតី រួមទាំងនៅលើប្រដាប់ភេទ ឬទ្វារធំផងដែរ។
- ប្រើប្រាស់ស្រោមអនាម័យ។ ការប្រើប្រាស់ស្រោមអនាម័យតែមួយមុខ ក៏មិនទំនងជាគ្រប់គ្រាន់ទេក្នុងការទប់ស្កាត់ការឆ្លងជំងឺអុតស្វា។ ប៉ុន្តែការប្រើប្រាស់ស្រោមអនាម័យប្រហែលជាអាចនឹងកាត់បន្ថយហានិភ័យបានផងដែរ ហើយក៏ថែមទាំងអាចនឹងជួយទប់ស្កាត់ការឡើងដំបៅនៅតំបន់ដែលងាយនឹងឈឺចាប់ខ្លាំងដូចជាទ្វារធំ មាត់ ឬប្រដាប់ភេទទៀតផង។
- កាត់បន្ថយចំនួនដៃគូរួមភេទ។
- ជៀសវាងសកម្មភាពដែលប្រឈមនឹងហានិភ័យខ្ពស់ជាងមុន ដូចជាការរួមភេទជាមួយអ្នកដែលមិនស្គាល់មុខ (anonymous sex) និងការរួមភេទជាមួយមនុស្សច្រើននាក់ក្នុងពេលតែមួយ (sex parties) ផងដែរ។

សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់គេហទំព័រ ការរួមភេទ និងការប្រមូលផ្តុំគ្នាសម្រាប់សកម្មភាពសង្គមដែលមានសុវត្ថិភាពជាងមុន ហើយនិងជំងឺអុតស្វា របស់មជ្ឈមណ្ឌលគ្រប់គ្រងនិងទប់ស្កាត់ជំងឺឆ្លង (CDC)។

## 12. តើមានថ្នាំបង្ការសម្រាប់ជំងឺអុតស្វាដែរឬទេ?

បាទ/ចាស។ មានថ្នាំបង្ការមួយប្រភេទហៅថា JYNNEOS បានទទួលការអនុម័តឱ្យប្រើប្រាស់ដោយរដ្ឋបាលចំណីអាហារនិងឱសថ (FDA) សម្រាប់ទប់ស្កាត់ការឆ្លងជំងឺអុតស្វាចំពោះមនុស្សទាំងឡាយដែលមានអាយុចាប់ពី 18 ឆ្នាំឡើងទៅ។ ថ្នាំបង្ការប្រភេទនេះក៏មានផ្តល់ជូនឱ្យប្រើប្រាស់សម្រាប់ជាករណី ការទទួលសិទ្ធិអនុញ្ញាតឱ្យប្រើប្រាស់ជាបន្ទាន់ (EUA) ពី FDA សម្រាប់បុគ្គលទាំងឡាយដែលមានអាយុក្រោម 18 ឆ្នាំផងដែរ។ ថ្នាំបង្ការនេះចាក់ជូនជាចំនួនពីរដូស។ ការចាក់ថ្នាំបង្ការប្រភេទ JYNNEOS ត្រូវការរយៈពេល 14 ថ្ងៃ ក្រោយពីការចាក់ដូសទីពីរ ដើម្បីទទួលបានការឆ្លើយតបភាពស៊ាំដែលល្អបំផុតទៅនឹងថ្នាំបង្ការ។ ប៉ុន្តែ បើទោះបីជាបានទទួលចាក់ថ្នាំបង្ការនោះតែចំនួនមួយដូស ក៏អាចជួយផ្តល់ប្រព័ន្ធការពារបានខ្លះផងដែរ។ គួរកត់សម្គាល់ជាសំខាន់ផងដែរថា មិនថាថ្នាំបង្ការចំនួនមួយដូស ឬពីរដូសអាចមានប្រសិទ្ធិភាព 100% ក្នុងការទប់ស្កាត់ការឆ្លងជំងឺនោះទេ។ ការបន្តអនុវត្តតាមវិធានការណ៍ផ្សេងៗ ដើម្បីកាត់បន្ថយហានិភ័យរបស់អ្នក នៅតែមានសារៈសំខាន់។

ប្រសិនបើមានការផ្តល់ជូនថ្នាំបង្ការ មុនពេលបុគ្គលម្នាក់បានប៉ះពាល់ទៅនឹងមេរោគអុតស្វា ថ្នាំបង្ការនោះអាចជួយការពារពួកគេពីការឆ្លងជំងឺអុតស្វាបាន។

ប្រសិនបើមានការផ្តល់ជូនថ្នាំបង្ការនោះ ក្រោយពីការប៉ះពាល់ទៅនឹងមេរោគអុតស្វា ថ្នាំបង្ការនោះអាចជួយទប់ស្កាត់ពួកគេពីការកើតជំងឺអុតស្វា ឬធ្វើឱ្យជំងឺនោះមានកម្រិតស្រាលជាងមុន។ គួរតែមានការផ្តល់ជូនថ្នាំបង្ការនោះក្នុងអំឡុងពេល 14 ថ្ងៃនៃការប៉ះពាល់ទៅនឹងមេរោគ (ជាពិសេសនៅអំឡុងពេល 4 ថ្ងៃដំបូង)។

***ប្រសិនបើនរណាម្នាក់មានផ្ទុកជំងឺអុតស្វារួចស្រេចហើយនោះ មិនមានការណែនាំឱ្យចាក់ថ្នាំបង្ការទេ។*** សម្រាប់ព័ត៌មានបន្ថែមអំពីថ្នាំបង្ការ សូមមើលគេហទំព័រ សំណួរដែលបានសួរជាញឹកញាប់អំពីថ្នាំបង្ការជំងឺអុតស្វា។

## 13. តើអ្នកណាខ្លះ មានសិទ្ធិអាចទទួលចាក់ថ្នាំបង្ការជំងឺអុតស្វាបាន?

**នាពេលឥឡូវនេះ ថ្នាំបង្ការមានផ្ដល់ជូនដល់៖**

- បុរស ឬបុគ្គលដែលបានផ្លាស់ប្ដូរភេទខុសពីដើមកំណើត (transgender) ណាម្នាក់ ដែលរួមភេទជាមួយនឹងបុរស ឬបុគ្គលដែលបានផ្លាស់ប្ដូរភេទខុសពីដើមកំណើតផ្សេងៗទៀត
- បុគ្គលទាំងឡាយដែលមានភេទណាក៏ដោយ ឬស្រឡាញ់ភេទណាក៏ដោយ ហើយដែលចូលរួមក្នុងការរួមភេទជាលក្ខណៈជំនួញ និង/ឬជាលក្ខណៈដោះដូរ (ឧ. ការរួមភេទដើម្បីទទួលបានប្រាក់ ទីជម្រក ម្ហូបអាហារ ឬក៏របស់របរឬតម្រូវការផ្សេងទៀត) ឬក៏រួមភេទដែលជាប់ពាក់ព័ន្ធជាមួយនឹងព្រឹត្តិការណ៍សាធារណៈធំមួយ
- បុគ្គលទាំងឡាយណាដែលកំពុងកើតមានមេរោគហ៊ីវ (HIV) ជាពិសេសអ្នកមានជំងឺ HIV ដែលមិនបានគ្រប់គ្រងត្រឹមត្រូវ ឬមានកម្រិតធ្ងន់ធ្ងរ
- បុគ្គលទាំងឡាយណាដែលមានការប៉ះពាល់ស្បែកនឹងស្បែក ឬការប៉ះពាល់ដោយស្និទ្ធស្នាល ជាមួយនឹងបុគ្គលម្នាក់ដែលមានការសង្ស័យថាមានជំងឺអុតស្វា ឬបានបញ្ជាក់យ៉ាងច្បាស់លាស់ថាមានជំងឺនេះ រួមទាំងបុគ្គលទាំងឡាយណាដែលមិនទាន់បានបញ្ជាក់យ៉ាងច្បាស់លាស់ដោយនាយកដ្ឋានសុខភាពសាធារណៈ (Public Health) ផងដែរ
- ដៃគូរួមភេទរបស់បុគ្គលទាំងឡាយនៅក្នុងក្រុមផ្សេងៗណាមួយខាងលើ
- បុគ្គលទាំងឡាយណាដែលរំពឹងទុកថានឹងស្ថិតនៅក្នុងក្រុមផ្សេងៗណាមួយខាងលើ។

ការមានសិទ្ធិអាចទទួលចាក់ថ្នាំបង្ការ អាចនឹងពង្រីកទៅដល់ក្រុមផ្សេងទៀត នាពេលអនាគត – សម្រាប់ព័ត៌មានថ្មីបំផុត សូមមើលគេហទំព័រ ph.lacounty.gov/monkeypox/vaccine.htm។

## 14. តើខ្ញុំអាចទទួលចាក់ថ្នាំបង្ការបានយ៉ាងដូចម្ដេច?

ប្រសិនបើអ្នកស្ថិតនៅក្នុងក្រុមមួយក្នុងចំណោមក្រុមទាំងឡាយដែលមានសិទ្ធិទទួលចាក់ថ្នាំបង្ការសម្រាប់ជំងឺអុតស្វានោះ សូមទៅកាន់ ទីតាំងចាក់ថ្នាំបង្ការរបស់នាយកដ្ឋានសុខភាពសាធារណៈ មួយ ឬក៏ចូលទៅកាន់គេហទំព័រ Myturn.ca.gov ដើម្បីស្វែងរកទីតាំងមួយដែលនៅជិតអ្នក។ នៅពេលដែលអ្នកទៅកាន់ទីតាំងនោះ សូមត្រៀមខ្លួនឱ្យបានរួចរាល់ក្នុងការអះអាងថា អ្នកបានស្របតាមល័ក្ខខ័ណ្ឌនៃការមានសិទ្ធិអាចទទួលចាក់ថ្នាំបង្ការជំងឺអុតស្វាបាន។

សូមចូលទៅកាន់គេហទំព័រ ph.lacounty.gov/monkeypox/vaccine.htm ដើម្បីស្វែងយល់ថាតើអ្នកមានសិទ្ធិទទួលចាក់ថ្នាំបង្ការ ឬទេ។

សូមមើល សំណួរដែលបានសួរជាញឹកញាប់អំពីថ្នាំបង្ការជំងឺអុតស្វា សម្រាប់ព័ត៌មានបន្ថែមអំពីការចាក់ថ្នាំបង្ការប្រភេទ JYNNEOS។

## 15. តើខ្ញុំគួរតែធ្វើអ្វីខ្លះ ប្រសិនបើខ្ញុំបានប៉ះពាល់ទៅនឹងមេរោគអុតស្វា?

**តាមដានសុខភាពរបស់អ្នក។** បុគ្គលទាំងឡាយណាដែលកើតមានជំងឺអុតស្វា ជាធម្មតា មានលេចឡើងនូវរោគសញ្ញានានានៅចន្លោះពេលពី 7 ទៅ 14 ថ្ងៃ (ហើយអាចឈានដល់ 21 ថ្ងៃ) បន្ទាប់ពីបានប៉ះពាល់ទៅនឹងមេរោគ។ អ្នកអាចបន្តធ្វើសកម្មភាពតាមទម្លាប់ប្រចាំថ្ងៃរបស់អ្នកបាន ដរាបណាអ្នកមិនមានចេញរោគសញ្ញាទេនោះ។ សូមត្រៀមខ្លួនឱ្យបានរួចរាល់ក្នុងការ ដាក់ខ្លួនឱ្យនៅដាច់ដោយឡែកពីអ្នកដទៃ ប្រសិនបើអ្នកកើតមានរោគសញ្ញានានានៃជំងឺអុតស្វា។

**ទទួលចាក់ថ្នាំបង្ការ** ប្រសិនបើអ្នកមិនទាន់បានបញ្ចប់ការចាក់លំដាប់ដំបូងនៃថ្នាំបង្ការជំងឺអុតស្វា ដែលមានចំនួនពីរដូសទេនោះ។ ការទទួលចាក់ថ្នាំបង្ការជំងឺអុតស្វាចំនួនមួយដូស ក្នុងអំឡុងពេល 4 ថ្ងៃក្រោយពីការប៉ះពាល់ទៅនឹងមេរោគ អាចជួយទប់ស្កាត់អ្នកពីការឆ្លងជំងឺនេះ។ ការទទួលចាក់ថ្នាំបង្ការក្នុងអំឡុងពេល 4 ទៅ 14 ថ្ងៃក្រោយពីការប៉ះពាល់ទៅនឹងមេរោគ អាចជួយធ្វើឱ្យការឆ្លងជំងឺរបស់អ្នកមានកម្រិតស្រាលជាងមុន។ សូមស្វែងយល់បន្ថែមនៅលើគេហទំព័រ ph.lacounty.gov/monkeypox/vaccine.htm។

**សូមទទួលទូរស័ព្ទពីនាយកដ្ឋានសុខភាពសាធារណៈ (Public Health)។** ប្រសិនបើអ្នកត្រូវបានស្គាល់ថាជាបុគ្គលដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយនឹងអ្នកដែលមានជំងឺអុតស្វានោះ Public Health អាចនឹងទាក់ទងទៅអ្នក ដើម្បីតាមដានមើលថាអ្នកមានអាការៈយ៉ាងណាដែរ ហើយនិងផ្ដល់ថ្នាំបង្ការ ប្រសិនបើសមស្រប។

**ពិនិត្យមើលនៅលើ** សេចក្ដីណែនាំសម្រាប់បុគ្គលទាំងឡាយដែលបានប៉ះពាល់ទៅនឹងមេរោគអុតស្វា សម្រាប់ព័ត៌មានបន្ថែម។

## 16. តើអ្នកដែលមានមេរោគហ៊ីវ (HIV) អាចធ្វើអ្វីបានខ្លះ ដើម្បីការពារខ្លួនពួកគេពីជំងឺអុតស្វា?

អ្នកដែលកំពុងកើតមានមេរោគហ៊ីវ (HIV) គួរតែអនុវត្តតាមសេចក្តីណែនាំផ្សេងៗដូចគ្នាទៅនឹងមនុស្សដទៃទៀតផងដែរ ដើម្បីការពារខ្លួនពួកគេពីការឆ្លងជំងឺអុតស្វា។ ទោះជាយ៉ាងណាក៏ដោយ មនុស្សដែលមានមេរោគ HIV គួរតែអនុវត្តតាមជំហានបន្ថែមទៀត។ ការធ្វើបែបនេះគឺពីព្រោះតែមានភស្តុតាងកាន់តែច្រើនទៅៗដែលថា ជំងឺអុតស្វាអាចកើតមានក្នុងកម្រិតកាន់តែធ្ងន់ធ្ងរនៅលើអ្នកដែលកំពុងកើតមានមេរោគ HIV ហើយដែលមានចំនួនកោសិកា CD4 ទាប (កោសិកាតិចជាងចំនួន 350 ក្នុងមួយមីលីលីត្រ [<350 cells/ml]) ឬក៏មានចំនួនមេរោគក្នុងខ្លួនដែលមិនបានបង្ក្រាប (unsuppressed viral load)។

តើអ្នកអាចធ្វើអ្វីបានខ្លះ ដើម្បីការពារខ្លួនអ្នក?

- ទទួលចាក់ថ្នាំបង្ការជំងឺអុតស្វា។ ថ្នាំបង្ការនេះគឺមានសុវត្ថិភាព និងអាចផ្តល់ជូនបានដោយការចាក់នៅចន្លោះស្រទាប់ស្បែក (intradermally) ឬការចាក់នៅក្រោមស្រទាប់ស្បែក (subcutaneously) ក៏បាន។
- ជៀសវាងការប៉ះពាល់ដោយផ្ទាល់ជាមួយនឹងកន្ទួលរមាស់ ឬសារធាតុរាវផ្សេងៗដែលបានបញ្ចេញមកក្រៅរបស់អ្នកដែលមានជំងឺអុតស្វា។ សូមមើលសំណួរ *តើខ្ញុំអាចកាត់បន្ថយកម្រិតហានិភ័យនៃការឆ្លងជំងឺអុតស្វារបស់ខ្ញុំបានយ៉ាងដូចម្តេច?*
- ត្រូវប្រាកដថាអ្នកគ្រប់គ្រងការឆ្លងមេរោគ HIV របស់អ្នកឱ្យបានត្រឹមត្រូវ។ ការទទួលប្រើប្រាស់ ថ្នាំប្រឆាំងនឹងមេរោគហ៊ីវ (antiretroviral therapy/ART) របស់អ្នកឱ្យបានទៀងទាត់តាមការណែនាំ គឺជាការសំខាន់។ ប្រសិនបើអ្នកត្រូវការជំនួយក្នុងការស្វែងរកគ្រូពេទ្យជំនាញផ្នែកជំងឺ HIV ឬក្នុងការធ្វើការណាត់ជួបនោះ បុគ្គលិករបស់នាយកដ្ឋានសុខភាពសាធារណៈ (Public Health) អាចជួយដល់អ្នកបានដោយចូលទៅកាន់គេហទំព័រ ph.lacounty.gov/dhsp/RapidART.htm ឬក៏ទូរស័ព្ទទៅកាន់លេខ 1-833-351-2298។

តើអ្នកគួរតែធ្វើដូចម្តេច ប្រសិនបើអ្នកគិតថាអ្នកអាចនឹងមានជំងឺអុតស្វា?

- ប្រសិនបើអ្នកកើតមានកន្ទួលរមាស់ ឬដំបៅថ្មីៗ ដែលអ្នកគិតថាអាចជាជំងឺអុតស្វានោះ សូមទៅជួបជាមួយនឹងគ្រូពេទ្យភ្លាមៗ។ សូមប្រាប់ដល់ពួកគេថាអ្នកមានជំងឺ HIV។
  - ប្រសិនបើគ្រូពេទ្យរបស់អ្នកសង្ស័យថាជាជំងឺអុតស្វាមែន ពួកគេអាចនឹងឱ្យអ្នកចាប់ផ្តើមទទួលថ្នាំព្យាបាលប្រឆាំងនឹងមេរោគ (antiviral treatment) សម្រាប់ជំងឺអុតស្វា (ថ្នាំប្រភេទ TPOXX) ភ្លាមៗ ជាពិសេសប្រសិនបើអ្នកមានជំងឺ HIV ដែលមិនបានគ្រប់គ្រងត្រឹមត្រូវ ឬមានកម្រិតធ្ងន់ធ្ងរ។ ប្រសិនបើជំងឺ HIV របស់អ្នកមានការគ្រប់គ្រងត្រឹមត្រូវ ប៉ុន្តែអ្នកកើតមានដំបៅនៅលើភ្នែក ក្នុងមាត់ ក្នុងចុងពោះវៀនធំ ឬនៅលើលិង្គនោះ ពួកគេអាចនឹងណែនាំឱ្យចាប់ផ្តើមទទួលថ្នាំប្រភេទ TPOXX ដើម្បីកាត់បន្ថយកម្រិតហានិភ័យនៃការឈឺចាប់ ការឆ្លងមេរោគ (ទៅក្នុងដំបៅទាំងនោះ) និងការចេញស្នាមសម្លាក ផងដែរ។
- ប្រសិនបើមានអ្នកទទួលបានវេជ្ជបញ្ជាឱ្យប្រើប្រាស់ថ្នាំប្រភេទ TPOXX ការទទួលថ្នាំប្រភេទនេះទៅតាមការណែនាំ គឺជាការសំខាន់។
- សម្រាប់ព័ត៌មានបន្ថែមសូមមើលសំណួរ *តើខ្ញុំគួរតែធ្វើអ្វីខ្លះ ប្រសិនបើខ្ញុំគិតថាខ្ញុំមានជំងឺអុតស្វា?*

សូមចូលទៅកាន់ចំណុច ព័ត៌មានថ្មីៗអំពីជំងឺអុតស្វា នៅលើគេហទំព័រ HIV.gov សម្រាប់ព័ត៌មានបន្ថែមអំពីជំងឺអុតស្វា និងជំងឺ HIV។

## 17. តើកុមារអាចឆ្លងជំងឺអុតស្វាបាន ដែរឬទេ?

ចាស/បាទ។ បុគ្គលណាម្នាក់ក៏អាចឆ្លងជំងឺអុតស្វាបានដែរ ប្រសិនបើពួកគេបានមានទំនាក់ទំនងជិតស្និទ្ធ ព្រមទាំងការប៉ះពាល់ផ្ទាល់ខ្លួន ឬការប៉ះពាល់ដោយស្និទ្ធស្នាលជាមួយនឹងនរណាម្នាក់ដែលមានជំងឺអុតស្វា។ ហានិភ័យនៃការឆ្លងជំងឺអុតស្វាទៅកាន់កុមារ នៅក្នុងអំឡុងពេលនៃការផ្ទុះឡើងនៃជំងឺនាពេលបច្ចុប្បន្ននេះ មានកម្រិតទាបណាស់។ ខណៈពេលដែលករណីឆ្លងមេរោគទាំងឡាយចំពោះកុមារ បានកើតមានឡើងនៅក្នុងសហរដ្ឋអាមេរិកមែន ប៉ុន្តែករណីទាំងនោះកម្រនឹងកើតមានណាស់។

កុមារតូចៗប្រឈមនឹងហានិភ័យខ្ពស់នៃការឆ្លងជំងឺអុតស្វា ប្រសិនបើពួកគេរស់នៅជាមួយនឹងនរណាម្នាក់ដែលមានជំងឺអុតស្វា ជាពិសេស ប្រសិនបើមានការប៉ះពាល់ស្បែកនឹងស្បែកក្នុងលក្ខណៈណាមួយជាមួយនឹងអ្នកផ្ទុកជំងឺនេះ។ ប្រសិនបើអ្នកមានជំងឺអុតស្វា ឬមានការសង្ស័យថាខ្លួនមានជំងឺអុតស្វានោះ សូមអនុវត្តតាមវិធានការណ៍នានា ដើម្បីការពារមនុស្សរាល់គ្នានៅក្នុងផ្ទះរបស់អ្នក។ សូមពិនិត្យមើល សេចក្តីណែនាំអំពីការដាក់ខ្លួនឱ្យនៅដាច់ដោយឡែកសម្រាប់បុគ្គលដែលមានជំងឺអុតស្វា។

មនុស្សពេញវ័យដែលមានទំនាក់ទំនងផ្លូវកាយដោយស្និទ្ធស្នាល ឬដែលសកម្មផ្នែកផ្លូវភេទជាមួយនឹងអ្នកដទៃ ក៏អាចប្រឈមនឹងហានិភ័យខ្ពស់ជាងមុននៃការឆ្លងជំងឺអុតស្វាផងដែរ។ ចំណុចនេះគឺជាការពិតជាពិសេស ប្រសិនបើពួកគេគឺជាមនុស្សភេទប្រុសដែលរួមភេទជាមួយនឹងមនុស្សភេទប្រុសដទៃទៀត។ សម្រាប់ព័ត៌មានបន្ថែម សូមមើលគេហទំព័រ ការរួមភេទ និងការប្រមូលផ្តុំគ្នាសម្រាប់សកម្មភាពសង្គមដែលមានសុវត្ថិភាពជាងមុន ហើយនិងជំងឺអុតស្វា របស់មជ្ឈមណ្ឌលគ្រប់គ្រងនិងទប់ស្កាត់ជំងឺឆ្លង (CDC)។

## 18. តើផលិតផលលាងសម្អាតប្រភេទណាខ្លះ ដែលអាចប្រឆាំងនឹងមេរោគអុតស្វាបាន?

ទីភ្នាក់ងារការពារបរិស្ថាន (EPA) នៃសហរដ្ឋអាមេរិក មានតារាងផលិតផលសម្លាប់មេរោគដែលបានចុះបញ្ជីការសម្រាប់ការប្រើប្រាស់ប្រឆាំងនឹងមេរោគអុតស្វា។ តារាងនោះរួមមានទាំងផលិតផលពេញនិយមផ្សេងៗ ដែលហាងអាជីវកម្ម និងបុគ្គលផ្ទាល់ខ្លួនជាច្រើន បានធ្លាប់ប្រើប្រាស់រួចផងដែរ។ តារាងនេះអាចរកបាននៅលើ គេហទំព័ររបស់ EPA។ គេហទំព័រនេះមាន ផ្នែកស្វែងរកមួយ សម្រាប់រកមើលផលិតផលសម្លាប់មេរោគតាមចំណុចផ្សេងៗ ដូចជាឈ្មោះផលិតផល រយៈពេលដែលផលិតផលត្រូវស្ថិតនៅលើផ្ទៃ និងប្រភេទផ្ទៃជាដើម។

- ពិនិត្យមើលថាផលិតផលនោះមានការចុះនៅក្នុងបញ្ជីរបស់ EPA ឬទេ។
- អានការណែនាំរបស់ក្រុមហ៊ុនផលិត។ ត្រូវប្រាកដថានោះជាផលិតផលដែលត្រឹមត្រូវសម្រាប់ការប្រើប្រាស់នៅលើផ្ទៃរបស់អ្នក។
- លាងសម្អាតផ្ទៃជាមុន ជាមួយនឹងសាប៊ូនិងទឹក ប្រសិនបើការណែនាំនៃផលិតផលនោះមានបញ្ជាក់ថាឱ្យធ្វើការលាងសម្អាតជាមុន ឬប្រសិនបើផ្ទៃនោះមើលឃើញច្បាស់ថាកខ្វក់។ ធូលីដីអាចរារាំងមិនឱ្យផលិតផលសម្លាប់មេរោគនោះ ដំណើរការបានត្រឹមត្រូវ។
- អនុវត្តតាមការណែនាំនៃការ ត្រូវឱ្យផលិតផលស្ថិតនៅលើផ្ទៃ។ ផ្ទៃនោះគួរតែទុកឱ្យនៅសើមទៅតាមរយៈពេលដែលបានបញ្ជាក់នោះលើផលិតផល ដើម្បីធានាថាផលិតផលមានប្រសិទ្ធិភាព។ សូមបាញ់ ឬលាបផលិតផលម្តងទៀត ប្រសិនបើចាំបាច់។

អាចប្រើប្រាស់សាប៊ូបោកគក់សម្លៀកបំពាក់ធម្មតាបាន សម្រាប់បោកគក់សម្អាតសម្លៀកបំពាក់ ឬកម្រាលក្រណាត់នានា (ឧ. កម្រាលពូកឬស្រោមខ្នើយ និងកន្សែងជូតខ្លួន) ដែលបានប្រើប្រាស់រួចដោយបុគ្គលដែលមានជំងឺអុតស្វា។

អាចដាក់លាងសម្អាតចាន និងឧបករណ៍បរិភោគអាហារដែលប្រឡាក់ នៅក្នុងម៉ាស៊ីនលាងចានបាន ជាមួយនឹងសាប៊ូលាងចាននិងទឹកក្តៅ ឬលាងសម្អាតដោយដៃជាមួយនឹងទឹកក្តៅនិងសាប៊ូលាងចាន។

សូមមើលចំណុច ការសម្អាតនិងការសម្លាប់មេរោគនៅតាមផ្ទះ កន្លែងធ្វើការ និងទីតាំងផ្សេងទៀតនៅក្នុងសហគមន៍របស់អ្នក របស់មជ្ឈមណ្ឌលគ្រប់គ្រងនិងទប់ស្កាត់ជំងឺឆ្លង (CDC) សម្រាប់ព័ត៌មានបន្ថែម និងគន្លឹះសម្រាប់ការលាងសម្អាត ក្នុងអំឡុងពេល និងក្រោយពេលមានការឆ្លងជំងឺអុតស្វា។

## 19. តើខ្ញុំអាចស្វែងរកព័ត៌មានបន្ថែមបាន នៅទីណាខ្លះ?

**នាយកដ្ឋានសុខភាពសាធារណៈ ខោនធី Los Angeles**
ph.lacounty.gov/monkeypox
ph.lacounty.gov/monkeypox/vaccine.htm

**មជ្ឈមណ្ឌលគ្រប់គ្រង និងទប់ស្កាត់ជំងឺឆ្លង (CDC)**
cdc.gov/poxvirus/monkeypox/index.html

**នាយកដ្ឋានសុខភាពសាធារណៈនៃរដ្ឋ California**
cdph.ca.gov/Programs/CID/DCDC/Pages/Monkeypox.aspx




County of Los Angeles Public Health